ទីស្តីការក្រសួងយុត្តិធម៌

លេខ ៨២១ ព្រទ ភហ-៩៥

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

លោកប្រធានតុលាការ ក្រុងភ្នំពេញ

**សូមជ្រាប។**

***កម្មវត្ថុ:*** អំពីដីកាឱ្យចូលខ្លួនលេខ ១៤០ ចុះថ្ងៃទី០៤-០៨-៩៥ របស់តុលាការក្រុងភ្នំពេញ ។

ខ្ញុំសូមជម្រាបលោកថា ក្រសួងយុត្តិធម៌បានទទួលពិនិត្យលើពាក្យបណ្តឹងរបស់ឈ្មោះ......ប្តឹងសុំឱ្យតុលាការក្រុងភ្នំពេញពន្យាពេលជំនុំជម្រះរឿងក្តីរបស់ខ្លួន ព្រោះថាការប្រគល់ដីកាកោះឱ្យចូលខ្លួនរបស់តុលាការក្រុងភ្នំពេញមុនពេលសវនាការតែមួយថ្ងៃគត់គឺបានទទួលដីកាកោះនៅថ្ងៃទី០៧-០៨-៩៥ វេលាម៉ោង១០ព្រឹក ហើយត្រូវជំនុំជម្រះនៅថ្ងៃទី០៨-០៨-៩៥ វេលាម៉ោង ៧ព្រឹក ។

ដើម្បីជៀសវាងការខុសឆ្គងដូចខាងលើនេះ ក្រសួងសូមរំលិកដល់លោកប្រធានថា ការចាត់ឱ្យធ្វើដីកាកោះអញ្ជើញគូភាគីក្នុងរឿង គឺត្រូវធ្វើនឹងប្រគល់ឱ្យបានមុនពេល ដែលតុលាការកំណត់ឱ្យចូលខ្លួនមកចំពោះមុខតុលាការក្នុងរយៈពេល១៥ថ្ងៃ នោះទើប មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

អាស្រ័យហេតុនេះ សូមលោកប្រធានយកចិត្តទុកដាក់អនុវត្តឱ្យបានត្រឹមត្រូវតាមនីតិវិធីតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៩៤

**រដ្ឋមន្ត្រី**

**ចែម ស្ងួន**

ចម្លងជូន

-តុលាការខេត្ត ក្រុង

-ដើម្បីអនុវត្ត